ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ:......០៤៨...........សក.ប្រក

ក្រសួងអភិវឌ្ឍន៍ជនបទ

# ប្រកាសអន្តរក្រសួង
## ស្តីពី
## នីតិវិធីនៃការធ្វើអធិការកិច្ចផ្លូវថ្នល់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

រដ្ឋមន្ត្រី
ក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នក/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នក/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ ស្តីពីឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដំឡើងនាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ ស្តីពីការប្រែក្លាយ និងដំឡើងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការនិងដឹកជញ្ជូន ទៅជាវិទ្យាស្ថានតេជោសែនសាធារណការ និងដឹកជញ្ជូន របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១**._

ប្រកាសនេះមានគោលបំណងធ្វើឱ្យប្រសើរលើការគ្រប់គ្រង ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងការធានាសុវត្ថិភាពចរាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងបរិស្ថានល្អ សំដៅបង្ការ និងទប់ស្កាត់រាល់អំពើល្មើសដែលមានចែងនៅក្នុងច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ តាមរយៈ៖

១-ការកំណត់សមត្ថកិច្ច និងនីតិវិធីសម្រាប់ការអនុវត្តការត្រួតពិនិត្យ និង/ឬការធ្វើអធិការកិច្ចលើការគ្រប់គ្រង និងការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។

២-ការជំរុញបុគ្គលដែលទទួលបានសិទ្ធិលើការអភិវឌ្ឍ ឬការធ្វើអាជីវកម្មលើវិស័យផ្លូវថ្នល់ ឬបុគ្គលពាក់ព័ន្ធ ឱ្យគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់។

៣-ការកំណត់វិធានការនានា ដោយអនុលោមតាមច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់។

**ប្រការ២**._

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣**._

វាក្យសព្ទដែលប្រើនៅក្នុងប្រកាសនេះ មានដូចខាងក្រោម៖

១-ការត្រួតពិនិត្យ សំដៅដល់សកម្មភាពរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ដែលចុះត្រួតពិនិត្យទីតាំង ឬហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសំណង់ផ្លូវថ្នល់នៅតាមបណ្តាញផ្លូវថ្នល់ ដើម្បីអង្កេត និងពិនិត្យ

អនុលោមភាពនៃបទដ្ឋានបច្ចេកទេស បទប្បញ្ញត្តិ និងសកម្មភាពផ្សេងៗដែលអាចបង្កជាបទល្មើស ដូចមានចែងនៅក្នុងច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីជំរុញការគោរពច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលនៅជាធរមាន។

២-ការធ្វើអធិការកិច្ចផ្លូវថ្នល់ សំដៅដល់ការតាមដាន ស្រាវជ្រាវ និងត្រួតពិនិត្យនៅតាមទីតាំងឬនៅតាមបណ្តាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសំណង់ផ្លូវថ្នល់នៅតាមបណ្តាញផ្លូវថ្នល់ ដើម្បីចាត់វិធានការដល់បុគ្គលដែលបានប្រព្រឹត្តអំពើល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

៣-សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ សំដៅដល់ក្រសួង-ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចមានចែងនៅក្នុងច្បាប់ស្តីពីផ្លូវថ្នល់ ហើយមានសិទ្ធិតែងតាំងនិងចេញលិខិតបញ្ជាបេសកកម្មដល់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ដើម្បីធ្វើការចុះត្រួតពិនិត្យ និង/ឬធ្វើអធិការកិច្ចសកម្មភាពពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់។

៤-មន្ត្រីអធិការកិច្ចផ្លូវថ្នល់ សំដៅដល់មន្ត្រីជំនាញថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានភារកិច្ចពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់ និងទទួលបានការតែងតាំងជាមន្ត្រីអធិការកិច្ចផ្លូវថ្នល់ ដើម្បីចុះត្រួតពិនិត្យ និង/ឬធ្វើអធិការកិច្ចលើសកម្មភាពពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់។

៥-ការពិន័យអន្តរការណ៍ សំដៅដល់ការដាក់ពិន័យដល់ម្ចាស់ទីតាំង ឬបុគ្គលដែលទទួលបានសិទ្ធិលើការអភិវឌ្ឍ ឬការធ្វើអាជីវកម្មលើវិស័យផ្លូវថ្នល់ ឬបុគ្គលពាក់ព័ន្ធ ដែលប្រព្រឹត្តអំពើល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

៦-ទីតាំង សំដៅដល់ការដ្ឋាន ឬតំបន់ណាមួយដែលមានសកម្មភាពពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់ ឬមន្ទីរពិសោធន៍ឯកជនដែលប្រកបអាជីវកម្មលើវិស័យផ្លូវថ្នល់។

៧-បុគ្គល សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល។

៨-បណ្តាញផ្លូវថ្នល់ សំដៅដល់គ្រប់ប្រភេទនៃផ្លូវថ្នល់ដែលមានទំនាក់ទំនងគ្នាជាបណ្តាញ រួមមានផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវជនបទ ផ្លូវរាជធានី ផ្លូវក្រុង ផ្លូវក្នុងទីប្រជុំជននានាក្នុងខេត្ត និងផ្លូវថ្នល់ផ្សេងទៀត ដែលកំណត់ដោយរាជរដ្ឋាភិបាល។

## ជំពូកទី២
## សមត្ថកិច្ច តួនាទី និងភារកិច្ច

**ប្រការ៤.-**

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ មានដូចខាងក្រោម៖

១-រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់។

២-អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់។

៣-សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ផ្សេងទៀត ដែលកំណត់ដោយរាជរដ្ឋាភិបាល។

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ មានសិទ្ធិពិនិត្យ និងចេញលិខិតបញ្ជាបេសកកម្មដល់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ដើម្បីចុះត្រួតពិនិត្យ និង/ឬធ្វើអធិការកិច្ចពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់។

**ប្រការ៥.-**

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ មានសិទ្ធិចេញលិខិតបញ្ជាបេសកកម្ម ដល់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ថ្នាក់ជាតិ ស្របតាមសមត្ថកិច្ចដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់។

អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត មានសិទ្ធិចេញលិខិតបញ្ជាបេសកកម្ម ដល់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ថ្នាក់ក្រោមជាតិ ស្របតាមសមត្ថកិច្ចដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់។

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ផ្សេងទៀត ដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល។

**ប្រការ៦.-**

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ទទួលពិនិត្យរបាយការណ៍របស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ និងមានសិទ្ធិដាក់ចេញនូវវិធានការចាំបាច់មួយ ឬច្រើន ដោយអនុលោមទៅតាមច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**ប្រការ៧.-**

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ មានដូចខាងក្រោម៖

១-មន្ត្រីជំនាញមានភារកិច្ចពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានសាធារណការ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន និងនាយកដ្ឋានព័ត៌មានវិទ្យានិងទំនាក់ទំនងសាធារណៈ នៃក្រសួងសាធារណការ និងដឹកជញ្ជូន។

២-មន្ត្រីជំនាញមានភារកិច្ចពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន និងនាយកដ្ឋានផ្លូវលំជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ។

៣-មន្ត្រីជំនាញមានភារកិច្ចពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់ នៃមន្ទីររាជធានី-ខេត្ត ក្រោមឱវាទក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ។

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវស្នើសុំលិខិតបញ្ជាបេសកកម្មចុះត្រួតពិនិត្យ និង/ឬធ្វើអធិការកិច្ចផ្លូវថ្នល់ ស្របតាមនីតិវិធីដូចមានចែងក្នុងប្រកាសនេះ ។

**ប្រការ៨.-**

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ មានសមត្ថកិច្ចក្នុងការចុះពិនិត្យ និង/ឬការធ្វើអធិការកិច្ចផ្លូវថ្នល់ ដោយអនុលោមតាមច្បាប់ស្តីពីផ្លូវថ្នល់ បទប្បញ្ញត្តិបច្ចេកទេស និងបទប្បញ្ញត្តិពាក់ព័ន្ធដែលនៅជាធរមាន។

**ប្រការ៩.-**

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវអនុវត្តសិទ្ធិ តួនាទី និងភារកិច្ចរបស់ខ្លួនស្របតាមច្បាប់ស្តីពីផ្លូវថ្នល់ បទប្បញ្ញត្តិបច្ចេកទេស និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀតដែលនៅជាធរមាន។

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវអនុវត្តសិទ្ធិ តួនាទី និងភារកិច្ចរបស់ខ្លួនដោយឯករាជ្យមិនលម្អៀង និងប្រកបដោយតម្លាភាព គណនេយ្យភាព ស័ក្តិសិទ្ធិភាព ព្រមទាំងមានការទទួលខុសត្រូវលើសកម្មភាពអធិការកិច្ចរបស់ខ្លួន។

# ជំពូកទី៣
# នីតិវិធីនៃការធ្វើអធិការកិច្ចផ្លូវថ្នល់

**ប្រការ១០.-**

រាល់ការចុះត្រួតពិនិត្យ និង/ឬការធ្វើអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវធ្វើឡើងជាប្រចាំយ៉ាងតិច ២ ដងក្នុង ១ ឆ្នាំ នៅតាមទីតាំង ឬលើសមាសភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសំណង់ផ្លូវថ្នល់នៅតាមបណ្តាញផ្លូវថ្នល់។

ការចុះអនុវត្តការត្រួតពិនិត្យ និង/ឬការធ្វើអធិការកិច្ចនៅតាមទីតាំង ត្រូវជូនដំណឹងជាមុនទៅម្ចាស់ទីតាំង ឬតំណាងស្របច្បាប់។ ការជូនដំណឹងនេះ គឺត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជូនដល់ម្ចាស់ទីតាំង ឬតំណាងស្របច្បាប់ ក្នុងរយៈពេលយ៉ាងតិច ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ មុនថ្ងៃចុះធ្វើការត្រួតពិនិត្យ និង/ឬការធ្វើអធិការកិច្ច។

**ប្រការ១១.-**

រាល់ការចុះត្រួតពិនិត្យ និង/ឬការធ្វើអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវមានការចូលរួមពីមន្ត្រីអធិការកិច្ចផ្លូវថ្នល់ចំនួន៖

១- ៥ (ប្រាំ) នាក់យ៉ាងតិច សម្រាប់ការធ្វើអធិការកិច្ចផ្លូវថ្នល់ថ្នាក់ជាតិ។

២- ៣ (បី) នាក់យ៉ាងតិច សម្រាប់ការធ្វើអធិការកិច្ចផ្លូវថ្នល់ថ្នាក់ក្រោមជាតិ។

**ប្រការ១២.-**

ក្នុងពេលចុះបំពេញបេសកកម្ម មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវ៖

១-មានលិខិតបញ្ជាបេសកកម្ម និងអត្តសញ្ញាណបណ្ណមន្ត្រីរាជការ។

២-ពាក់បណ្ណសម្គាល់មន្ត្រីអធិការកិច្ចផ្លូវថ្នល់។

៣-ប្រើប្រាស់ឯកសណ្ឋានផ្លូវការរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់។

៤-ប្រើប្រាស់ឯកសណ្ឋានការពារសុវត្ថិភាព ក្នុងករណីចាំបាច់។

**ប្រការ១៣.-**

ការចុះត្រួតពិនិត្យ និង/ឬការធ្វើអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់នៅតាមទីតាំង អាចធ្វើឡើងជាញឹកញាប់ និងតាមការចាំបាច់។ ការចុះត្រួតពិនិត្យ និង/ឬការធ្វើអធិការកិច្ចជាញឹកញាប់ និងតាមការចាំបាច់ត្រូវអនុវត្តចំពោះ៖

១-ករណីមានការសង្ស័យលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសំណង់ផ្លូវថ្នល់នៅតាមទីតាំង មិនអនុលោមតាមស្តង់ដារបច្ចេកទេស ឬបទប្បញ្ញត្តិបច្ចេកទេស ឬនីតិវិធីនៃការវាយតម្លៃអនុលោមភាព។

២-ករណីមានបណ្តឹង ឬមានការសង្ស័យទាក់ទងនឹងហានិភ័យខ្ពស់ ឬការប៉ះពាល់ខ្លាំងដល់គុណភាព សុវត្ថិភាព សណ្តាប់ធ្នាប់ ឬបរិស្ថាននៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសំណង់ផ្លូវថ្នល់។

៣-ករណីមានការស្រាវជ្រាវឃើញថា ដំណើរការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់និងសំណង់ផ្លូវថ្នល់ មិនគោរពតាមស្តង់ដារបច្ចេកទេស ឬបទប្បញ្ញត្តិបច្ចេកទេស ឬនីតិវិធីនៃការវាយតម្លៃអនុលោមភាព។

ករណីការចុះត្រួតពិនិត្យ និង/ឬការធ្វើអធិការកិច្ច ដូចមានចែងក្នុងចំណុចទាំង ៣ ខាងលើនេះ នឹងមិនមានការជូនដំណឹងជាមុនដល់ម្ចាស់ទីតាំង ឬតំណាងស្របច្បាប់ នោះឡើយ។

**ប្រការ១៤**._

មន្ត្រីអធិការកិច្ចផ្លូវថ្នល់អាចចូលបំពេញការងារនៅក្នុងទីតាំងបាន លុះត្រាតែមានការចូលរួម ឬមានវត្តមានម្ចាស់ទីតាំង ឬតំណាងស្របច្បាប់ ហើយទីតាំងកំពុងដំណើរការ។

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវចូលបំពេញការងារនៅក្នុងទីតាំង ដោយបើកចំហជាសាធារណៈ និងនៅក្នុងម៉ោងបំពេញការងារ គឺចាប់ពីម៉ោង ៦ ព្រឹក ដល់មុនម៉ោង ១៨ រសៀល។

**ប្រការ១៥**._

ការចុះត្រួតពិនិត្យ និង/ឬការធ្វើអធិការកិច្ចផ្លូវថ្នល់របស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ នៅតាមទីតាំង អាចធ្វើឡើងនៅក្រោយម៉ោង ១៨ រសៀល និងមុនម៉ោង ៦ ព្រឹកបាន លុះត្រាទទួលបានការអនុញ្ញាតពី ព្រះរាជអាជ្ញាជាមុន។

**ប្រការ១៦**._

ក្នុងពេលចុះបំពេញបេសកកម្មនៅតាមបណ្តាទីតាំង មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវ៖

១-ត្រួតពិនិត្យអាជ្ញាបណ្ណ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការប្រកបអាជីវកម្ម។

២-ត្រួតពិនិត្យសុវត្ថិភាពការងារនៅក្នុងនិងជុំវិញបរិវេណទីតាំង។

៣-ត្រួតពិនិត្យឯកសារពាក់ព័ន្ធនឹងគម្រោងសាងសង់ អភិវឌ្ឍ ស្តារ ឬជួសជុលបណ្តាញហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សំណង់ផ្លូវថ្នល់ ឬគម្រោងប្រកបអាជីវកម្មលើវិស័យផ្លូវថ្នល់។

៤-ត្រួតពិនិត្យអនុលោមភាពនៃច្បាប់ បទដ្ឋានបច្ចេកទេស បទប្បញ្ញត្តិបច្ចេកទេស និងបទដ្ឋានគតិយុត្តផ្សេងៗនៅជាធរមាន។

៥-ស្នើសុំម្ចាស់ទីតាំង ឬតំណាងស្របច្បាប់ នូវឯកសារពាក់ព័ន្ធផ្សេងៗ ជាអាទិ៍ លិខិតអនុញ្ញាតសាងសង់ អភិវឌ្ឍ ស្តារ ជួសជុល គម្រោងប្លង់ កិច្ចសន្យាម៉ៅការសាងសង់ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្មលើវិស័យផ្លូវថ្នល់។

៥-ប្រតិបត្តិការងារផ្សេងទៀតតាមការណែនាំពីថ្នាក់ដឹកនាំ ដោយអនុលោមតាមច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលនៅជាធរមាន។

**ប្រការ១៧**._

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវធ្វើកំណត់ហេតុនៃការចុះត្រួតពិនិត្យ និង/ឬការធ្វើអធិការកិច្ច ហើយកំណត់ហេតុត្រូវបានចុះហត្ថលេខា ឬផ្តិតស្នាមមេដៃដោយមន្ត្រីអធិការកិច្ចផ្លូវថ្នល់ និងម្ចាស់ទីតាំង ឬតំណាងស្របច្បាប់ បន្ទាប់ពីបានអាន ពិនិត្យ និងឯកភាពលើខ្លឹមសារទាំងស្រុងនៃកំណត់ហេតុនោះ។

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវធ្វើរបាយការណ៍ស្តីពីការចុះត្រួតពិនិត្យ និង/ឬការធ្វើអធិការកិច្ច និងត្រូវរៀបចំរបាយការណ៍ជូនសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃបានបញ្ចប់បេសកកម្ម។

**ប្រការ១៨**._

ក្នុងពេលចុះបំពេញបេសកកម្មត្រួតពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសំណង់ផ្លូវថ្នល់នៅតាមបណ្តាញផ្លូវថ្នល់ មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវប្រតិបត្តិ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**ប្រការ១៩.-**

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវចុះត្រួតពិនិត្យ និង/ឬធ្វើអធិការកិច្ចផ្លូវថ្នល់លើសមាសភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់និងសំណង់ផ្លូវថ្នល់នៅតាមបណ្តាញផ្លូវថ្នល់ ដោយអនុលោមតាមនីតិវិធីដូចមានចែងក្នុងវាក្យខណ្ឌទី ១ ប្រការ ១០ នៃប្រកាសនេះ ឬអនុលោមតាមភាពចាំបាច់ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ឬមានការសង្ស័យទាក់ទងនឹងហានិភ័យខ្ពស់ ឬការប៉ះពាល់ខ្លាំងដល់គុណភាព សុវត្ថិភាព សណ្តាប់ធ្នាប់ ឬបរិស្ថាននៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសំណង់ផ្លូវថ្នល់។

**ប្រការ២០.-**

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ មិនត្រូវធ្វើសកម្មភាពដូចខាងក្រោម៖

១-បង្កឱ្យមានការប៉ះពាល់ ឬរំខានដល់ដំណើរការការងារនៅក្នុងទីតាំង។

២-ប្រតិបត្តិការងាររបស់ខ្លួន ដោយមិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៣-ផ្សព្វផ្សាយជាសាធារណៈនូវខ្លឹមសារបច្ចេកទេស កំណត់ហេតុ របាយការណ៍ ឬឯកសារពាក់ព័ន្ធផ្សេងៗ។

**ប្រការ២១.-**

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវមានការទទួលខុសត្រូវ និងរក្សាការសម្ងាត់រាល់ព័ត៌មាន និងឯកសារពាក់ព័ន្ធដែលប្រមូលបានពីការចុះត្រួតពិនិត្យ និង/ឬការធ្វើអធិការកិច្ច លើកលែងតែមានការអនុញ្ញាតដោយច្បាប់ ដោយសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ឬដោយសេចក្តីបង្គាប់ពីតុលាការ។

## ជំពូកទី៤

## វិធានការ និងបណ្តឹងតវ៉ា

**ប្រការ២២.-**

ម្ចាស់ទីតាំង ឬតំណាងស្របច្បាប់ ត្រូវផ្តល់កិច្ចសហការជាមួយមន្ត្រីអធិការកិច្ចផ្លូវថ្នល់ ក្នុងការត្រួតពិនិត្យ និង/ឬការធ្វើអធិការកិច្ច ដូចមានចែងក្នុងប្រកាសនេះ។

ម្ចាស់ទីតាំង ឬតំណាងស្របច្បាប់ ឬបុគ្គលណាម្នាក់ដែលរារាំង រំខាន ឬបង្កបញ្ហាផ្សេងៗដល់ការប្រតិបត្តិការងាររបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

**ប្រការ២៣.-**

ក្នុងករណីពិនិត្យឃើញថា ដំណើរការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសំណង់ផ្លូវថ្នល់ ឬការប្រកបអាជីវកម្មលើវិស័យផ្លូវថ្នល់ មិនអនុលោមតាមលិខិតអនុញ្ញាត បទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់ បទប្បញ្ញត្តិបច្ចេកទេស ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ មន្ត្រីអធិការកិច្ចផ្លូវថ្នល់អាចចាត់វិធានការ៖

១-ប្រមូលនិងដកហូតភស្តុតាងពាក់ព័ន្ធផ្សេងៗ និងធ្វើកំណត់ហេតុភ្លាមៗនៅនឹងកន្លែង ដោយមានការចូលរួមពិនិត្យពីម្ចាស់ទីតាំង ឬអ្នកតំណាងស្របច្បាប់ លើកំណត់ហេតុនោះ។

២-ចាត់វិធានការផ្អាកជាបណ្តោះអាសន្ននូវសកម្មភាពដែលបានបង្ក ឬបណ្តាលឱ្យកើតមានការរំលោភអនុលោមភាពនៃបទប្បញ្ញត្តិ។

៣-រៀបចំរបាយការណ៍ជូនសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ និងលើកសំណើចាត់វិធានការមួយ ឬច្រើនដូចខាងក្រោម៖

-ព្រមានជាលាយលក្ខណ៍អក្សរ

-ផ្អាកសកម្មភាពនៅក្នុងទីតាំងជាបណ្តោះអាសន្ន

-ព្យួរ ឬដកហូតអាជ្ញាបណ្ណ

-ដកហូតទុកបណ្តោះអាសន្ននូវសម្ភារបរិក្ខារ និង/ឬគ្រឿងចក្រដែលពាក់ព័ន្ធនឹងបទល្មើស

-និង/ឬចាត់វិធានការផ្សេងទៀតតាមការចាំបាច់ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ក្នុងករណីមិនឯកភាពចំពោះវិធានការ ដែលធ្វើឡើងដោយមន្ត្រីអធិការកិច្ចផ្លូវថ្នល់ ម្ចាស់ទីតាំង ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីវិធានការខាងលើ។

**ប្រការ២៤._**

ក្នុងករណីបានពិនិត្យឃើញថា ដំណើរការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសំណង់ផ្លូវថ្នល់ ឬការប្រកបអាជីវកម្មលើវិស័យផ្លូវថ្នល់ មិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់ បទប្បញ្ញត្តិបច្ចេកទេស ឬលិខិតបទដ្ឋានគតិយុត្តណាមួយដែលគ្រប់គ្រាន់សម្រាប់ការពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវរៀបចំរបាយការណ៍ជូនសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ដើម្បីពិនិត្យនិងសម្រេច ដោយត្រូវបញ្ជាក់ឱ្យបានច្បាស់នូវព័ត៌មានដូចខាងក្រោម៖

១-អត្តសញ្ញាណម្ចាស់ទីតាំង ឬបុគ្គលបង្កបទល្មើស។

២-បទល្មើសដែលនាំឱ្យមានការពិន័យអន្តរការណ៍។

៣-ចំនួនទឹកប្រាក់ដែលត្រូវពិន័យអន្តរការណ៍។

ក្នុងករណីមិនឯកភាពចំពោះវិធានការពិន័យអន្តរការណ៍ ដែលធ្វើឡើងដោយមន្ត្រីអធិការកិច្ចផ្លូវថ្នល់ ម្ចាស់ទីតាំង ឬតំណាងស្របច្បាប់ អាចដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានលិខិតពិន័យអន្តរការណ៍។

**ប្រការ២៥._**

ក្នុងករណីពិនិត្យឃើញថាមានបុគ្គលណាម្នាក់បានបង្កសកម្មភាពដែលអាចបណ្តាលឱ្យអន្តរាយដល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសំណង់ផ្លូវថ្នល់ ឬបង្កឧបសគ្គដល់សុវត្ថិភាពចរាចរណ៍ ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលនៅជាធរមាន មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវចាត់វិធានការបង្ការ និងទប់ស្កាត់ជាបន្ទាន់ ព្រមទាំងធ្វើការណែនាំ ឬព្រមានជាលាយលក្ខណ៍អក្សរដល់បុគ្គលដែលបានបង្កសកម្មភាពនោះ។

ក្នុងករណីបុគ្គលដែលបង្កសកម្មភាពអន្តរាយ មិនបញ្ឈប់សកម្មភាពរបស់ខ្លួន មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវរាយការណ៍ ឬធ្វើរបាយការណ៍ជូនដល់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ និងស្នើនូវវិធានការចាំបាច់នានាដូចមានចែងក្នុងច្បាប់ស្តីពីផ្លូវថ្នល់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលនៅជាធរមាន។

ក្នុងករណីមិនឯកភាពចំពោះវិធានការដែលធ្វើឡើងដោយមន្ត្រីអធិការកិច្ចផ្លូវថ្នល់ បុគ្គលនោះអាចដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីវិធានការតាមផ្លូវច្បាប់។

**ប្រការ២៦._**

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ត្រូវសម្រេចលើបណ្តឹងតវ៉ារបស់ម្ចាស់ទីតាំង ឬតំណាងស្របច្បាប់ ឬបុគ្គលពាក់ព័ន្ធ ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យបណ្តឹង។

ក្នុងករណីសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ មិនឆ្លើយតបក្នុងរយៈពេលដូចកំណត់ក្នុងវាក្យខណ្ឌខាងលើ ឬមិនឯកភាពចំពោះសេចក្តីសម្រេចរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ម្ចាស់ទីតាំង ឬតំណាងស្របច្បាប់ ឬបុគ្គលពាក់ព័ន្ធអាចធ្វើបណ្តឹងទៅតុលាការ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃកំណត់ត្រូវទទួលបានការឆ្លើយតប ឬគិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច។

**ប្រការ២៧.**_

នៅពេលផុតរយៈពេល ៣០ (សាមសិប) ថ្ងៃនៃបណ្តឹងតវ៉ា ម្ចាស់ទីតាំង ឬបុគ្គលដែលប្រព្រឹត្តអំពើល្មើសមិនដាក់ពាក្យបណ្តឹងតវ៉ា និងមិនបង់ប្រាក់ពិន័យអន្តរការណ៍ សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ត្រូវរៀបចំសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូង ស្របតាមនីតិវិធីដូចមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលនៅជាធរមាន។

**ប្រការ២៨.**_

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់ស្តីពីផ្លូវថ្នល់ ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ២៩.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣០.**_

នាយកខុទ្ទកាល័យ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានគ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ និងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមការទទួលខុសត្រូវរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ [illegible]

ថ្ងៃសុក្រ ១០កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២២

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**រដ្ឋមន្ត្រី**
**ក្រសួងអភិវឌ្ឍន៍ជនបទ**

បណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ **សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី**
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី-ខេត្ត
- ដូចប្រការ៣០
- ឯកសារ-កាលប្បវត្តិ